# ការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

# ផ្នែក 2

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុង រឿងក្តីរដ្ឋប្បវេណី

# សេចក្តីពន្យល់បន្ថែម

ថ្ងៃទី 21 ខែកុម្ភៈ ឆ្នាំ2018

ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់
MAEDA Yuta

- Slide 3

បញ្ហាត្រង់ថា នៅពេលដែលតុលាការមិនទទួលស្គាល់ពាក្យសុំ តើត្រូវចេញដីកាសម្រេច "លើកចោល" ឬ ដីកាសម្រេច "ច្រានចោល"? ចំពោះបញ្ហានេះ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៤៤ កថាទី១ បានប្រើប្រាស់ពាក្យថា "លើកចោល" ដូច្នេះ ហើយក្នុងការអនុវត្តជាក់ស្តែងដែលតុលាការបានចេញដីកាសម្រេចលើកចោលនោះ គឺមានភាពត្រឹមត្រូវ។

- Slide 4

បើកម្មវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន គឺជាសិទ្ធិលើបំណុល សិទ្ធិលើបំណុលនោះនឹងស្ថិតនៅសមត្ថកិច្ចតុលាការរបស់កូនបំណុលទី៣ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៤០ កថា.ទី៣ និង មាត្រា ៨ កថា.ទី២) ដូច្នេះហើយ ប្រសិនបើកម្មវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្នគឺជាប្រាក់បញ្ញើក្នុងធនាគារ មានន័យថា ប្រាក់បញ្ញើនោះនឹងត្រូវស្ថិតនៅទីតាំងនៃអាសយដ្ឋានការិយាល័យកណ្តាលរបស់ធនាគារ។

សមត្ថកិច្ចក្នុងការរឹបអូសជាបណ្តោះអាសន្នក៏មាននៅ "សាលាដំបូងដែលមានសមត្ថកិច្ចចំពោះទីកន្លែងដែលវត្ថុត្រូវរឹបអូសជាបណ្តោះអាសន្នស្ថិតនៅផងដែរ" ហេតុនេះហើយ ទោះបីជា នៅក្រោយពេលដែលដាក់ពាក្យបណ្តឹងអង្គសេចក្តីក៏ដោយ ក៏មិនមែនមានន័យថា សមត្ថកិច្ចតុលាការនៃការរឹបអូសជាបណ្តោះអាសន្ន ត្រូវតែជាតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តីនោះទេ។ ឧទាហរណ៍ ៖ ទោះបីជាបណ្តឹងអង្គសេចក្តីបានដាក់នៅតុលាការតាមខេត្តក៏ដោយ ក៏ភាគីអាចដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្ននូវប្រាក់បញ្ញើក្នុងធនាគារដែលមានការិយាល័យកណ្តាលនៅទីក្រុងភ្នំពេញ មកសាលាដំបូងរាជធានីភ្នំពេញបានដែរ។

មូលហេតុដែលជំរុញឲ្យភាគីដកពាក្យសុំ ក្នុងករណីដែលបានដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្នមកតុលាការដែលគ្មានសមត្ថកិច្ចគឺ មានដូចតទៅ៖

ពោល គឺ យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២១ ដោយសារតែ ភាគីម្ខាងទៀតក៏អាចប្តឹងជំទាស់បានចំពោះដីកាសម្រេចផ្ទេរ ហេតុនេះហើយចាំបាច់ត្រូវតែប្រាប់ទៅភាគីម្ខាងទៀតអំពីដីកាសម្រេចផ្ទេរ។ មួយវិញទៀត បើដីកាសម្រេចផ្ទេរមិនទាន់ចូលជាស្ថាពរទេ នោះជាក់ស្តែង ការផ្ទេរក៏មិនអាចធ្វើឡើងបានដែរ។ បើមើលពីចំណុចទាំងនេះទៅ ឃើញថា ក្នុងករណីដែលតុលាការបានចេញដីកាសម្រេចផ្ទេរ នោះភាគីម្ខាងទៀតនឹងដឹងអំពីពាក្យសុំរក្សាការពារ ហើយប្រហែលជាអាចលាក់បាំងនូវទ្រព្យសម្បត្តិទៀតផង ម្យ៉ាងទៀតក៏ត្រូវចំណាយពេលនៃការផ្ទេរផងដែរ។

- Slide 5

តុលាការដែលមានសមត្ថកិច្ចមានចំនួនច្រើន ដូច្នេះភាគីអាចដាក់ពាក្យសុំទៅតុលាការមួយណាក៏បាន។

សមត្ថកិច្ចតុលាការត្រូវតែជ្រើសរើសនៅពេលដាក់ពាក្យសុំ។ ក្រោយមក បើទោះបីជាភាគីបានដាក់

ពាក្យបណ្ដឹងអង្គសេចក្ដីទៅតុលាការផ្សេងទៀតក៏ដោយ ក៏មិនចាំបាច់ធ្វើការផ្ទេរជាអាទិ៍ដែរ។

ឧទាហរណ៍៖ ម្ចាស់បំណុលបានដាក់ពាក្យសុំមកសាលាដំបូងរាជធានីភ្នំពេញដើម្បីរឹបអូសជាបណ្ដោះអាសន្ននូវដីដែលមានទីតាំងនៅតាមខេត្ត ដោយមូលហេតុ កូនបំណុលកំពុងតែរស់នៅទីក្រុងភ្នំពេញជាអាទិ៍។

- Slide 6

"ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលភាគីទាមទារ" ក៏ទាក់ទងទៅនឹងការសរសេរសេចក្ដីសម្រេចបញ្ចប់ផងដែរ។

" សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារ ត្រូវតែសរសេរឲ្យបានច្បាស់លាស់ ហើយគប្បីសរសេរនូវភស្ដុតាងតាមហេតុនីមួយៗដែលត្រូវបញ្ជាក់" គឺមានន័យថា ភាគីត្រូវតែអះអាងឲ្យបានលម្អិតអំពីអង្គហេតុចម្បង ហើយត្រូវបញ្ជាក់ច្បាស់ថា តើអង្គហេតុនីមួយៗមានភ្ជាប់សេចក្ដីបញ្ជាក់ដំបូងមកជាមួយដែរឬទេ?

- Slide 7

ដើម្បីជៀសវាងការលាក់បាំងពីកូនបំណុល នៅពេលនោះតុលាការមិនជូនដំណឹងទៅកាន់កូនបំណុល ឬ ស្ដាប់ការលើកឡើងរបស់កូនបំណុលជាអាទិ៍នោះទេ ដោយសារតែការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណីទាមទារឲ្យមានការសម្ងាត់។

- Slide 8

លក្ខខណ្ឌចាំបាច់នៃបណ្ដឹងគឺ សមត្ថកិច្ចតុលាការ សមត្ថភាពក្នុងការធ្វើបណ្ដឹង និង លក្ខណៈសម្បត្តិនៃភាគីជាអាទិ៍។ ចំណុចទាំងនេះតុលាការចាំបាច់ត្រូវតែស្រាវជ្រាវដោយឆន្ទានុសិទ្ធិ។ យ៉ាងណាមិញ ចំពោះសមត្ថកិច្ចតុលាការវិញ ប្រសិនបើតាំងពីដំបូងឡើយតុលាការមិនអាចចាត់ចែងលើបណ្ដឹងអង្គសេចក្ដីបានទេ នោះក៏មិនមានសមត្ថកិច្ចតុលាការទៅលើការរក្សាការពារដែរ។

" តើបានសរសេរអំពីចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំទេ?" សំដៅទៅលើថា តើអង្គហេតុចម្បងគ្រប់គ្រាន់ឬនៅ? តើខ្លឹមសារនៃដីកាសម្រេចដែលទាមទារត្រឹមត្រូវហើយឬនៅ ?ជាអាទិ៍។

- Slide 9

នៅក្នុងការរក្សាការពារនៃរឿងក្ដីរដ្ឋប្បវេណី "សិទ្ធិដែលនឹងត្រូវបានរក្សាការពារ" គឺមានសារៈសំខាន់ខ្លាំងណាស់។ ដូច្នេះហើយ នៅពេលដែលតុលាការចាត់ចែងរឿងក្ដីស្ដីពីការរក្សាការពារ គេគិតថាជាការប្រសើរតុលាការគួរតែមានទម្លាប់គិតថា តើសិទ្ធិដែលនឹងត្រូវបានរក្សាការពារ គឺជាអ្វី? តើអាចនិយាយបានថា មានសិទ្ធិបែបនោះដែរទេ?

មូលហេតុដែលទាមទារឲ្យត្រូវតែមានការឆ្លើយតបចំពោះការតវ៉ា ក្នុងករណីដែលតុលាការអាចព្យាករណ៍បានច្បាស់លាស់ថានឹងមានការតវ៉ា គឺដោយសារតែនៅក្នុងបណ្ដឹងអង្គសេចក្ដី តុលាការអាចនឹង

មិនទទួលស្គាល់នូវសិទ្ធិរបស់ដើមចោទ (ម្ចាស់បំណុល)ក្នុងកម្រិតខ្ពស់ ហេតុនេះហើយគឺអាចនិយាយបានថា គ្មានភាពចាំបាច់នៃការរក្សាការពារតាំងពីដំបូងមកម្ល៉េះ។

- Slide 10

  មូលហេតុដែលចាំបាច់ត្រូវតែកំណត់អំពីសិទ្ធិដែលនឹងត្រូវបានរក្សាការពារមានដូចខាងក្រោម៖

  ① ឲ្យកូនបំណុលអាចដឹងអំពីមូលហេតុនៃការរឹបអូសជាបណ្តោះអាសន្ន (សិទ្ធិដែលនឹងត្រូវបានរក្សាការពារ) ហើយផ្តល់ឱកាសឲ្យកូនបំណុលមានវិវាទលើចំណុចនេះ ។

  ② នៅពេលដែលដល់ពេលត្រូវផ្ទេរទៅជាការអនុវត្តដោយបង្ខំពិតប្រាកដវិញ ឬ បង្គាប់ឲ្យដាក់ពាក្យបណ្តឹងអង្គសេចក្តី (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៥៧ កថា.ទី១ ) ជាអាទិ៍ តុលាការចាំបាច់ត្រូវធ្វើការវិច្ឆ័យទៅលើភាពដូចគ្នានៃសិទ្ធិនេះ។

- Slide 11

  ចំណុចសំខាន់មាន២ ដូចខាងក្រោមនេះ៖

  ① កំណត់អំពីអង្គហេតុចម្បង។ ឧទាហរណ៍ ប្រសិនបើជាករណីខ្ចីបរិភោគ គឺចាំបាច់ត្រូវមានការសរសេរអំពីកម្មវត្ថុ និង កាលបរិច្ឆេទសង ព្រមទាំងថ្ងៃចុះកិច្ចសន្យាដូចមានចែងក្នុងក្រមរដ្ឋប្បវេណី មាត្រា ៥៧៨។ ប្រសិនបើជាករណីកិច្ចសន្យាលក់ទិញ ក្រៅពីត្រូវមានកាលបរិច្ឆេទនៃកិច្ចសន្យាហើយ គឺចាំបាច់ត្រូវមានការសរសេរអំពី កម្មវត្ថុ និង ចំនួនទឹកប្រាក់នៃការលក់ទិញដូចនៅក្នុងក្រមរដ្ឋប្បវេណី មាត្រា ៥១៥ ។

  ② នៅពេលដែលមានការទាមទារចំពោះសិទ្ធិលើបំណុលចាប់ពី ២ ឡើងទៅ ចាំបាច់ត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់នូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗ ។ បើយោងតាមឧទាហរណ៍ចំណុចទី①ខាងលើវិញ ដោយសារតែម្ចាស់បំណុលទាមទារនូវប្រាក់កម្ចី និង ការប្រាក់ ហេតុនេះហើយត្រូវតែបញ្ជាក់អំពីចំនួននៃទឹកប្រាក់នីមួយៗឲ្យបានច្បាស់។

- Slide 12

  ទាក់ទងនឹងការលើកឡើងថា កម្មវត្ថុចាំបាច់ត្រូវតែជាទ្រព្យសម្បត្តិរបស់កូនបំណុល គឺមានបញ្ហាមួយថា តើអាចធ្វើការរឹបអូសជាបណ្តោះអាសន្ននូវប្រាតិភោគពីរឿងក្តីរដ្ឋប្បវេណី (រឿងក្តីព្រហ្មទណ្ឌ) ដែលត្រូវបានដាក់តម្កល់នៅតុលាការដែរឬទេ? ដោយហេតុថា ប្រាក់ គឺប្រៀបបាននឹងកម្មសិទ្ធិ និង ការកាន់កាប់ ដូច្នេះហើយ ប្រាតិភោគដែលត្រូវបានដាក់តម្កល់នៅតុលាការនឹងត្រូវក្លាយជាកម្មសិទ្ធិរបស់រដ្ឋ (តុលាការ) ហេតុនេះ មិនអាចធ្វើការរឹបអូសជាបណ្តោះអាសន្នបានទេ។ ប៉ុន្តែ អ្នកបានដាក់ប្រាតិភោគតម្កល់ គឺមានសិទ្ធិទាមទារឲ្យរដ្ឋសងនូវប្រាក់ប្រាតិភោគមកវិញបាន។ ដូច្នេះ ក្នុងករណីដែលកូនបំណុលបានដាក់ប្រាតិភោគតម្កល់ ម្ចាស់បំណុលគួរតែធ្វើការរឹបអូសជាបណ្តោះអាសន្ននូវសិទ្ធិទាមទារឲ្យសង

ប្រាក់តម្កល់ដែលកូនបំណុលមាន ដោយយករដ្ឋធ្វើជាកូនបំណុលទី៣ ។

ដោយសារតែត្រូវតែកំណត់អំពីកម្មវត្ថុ ហេតុនេះហើយមិនអាចដាក់ពាក្យសុំដែលសរសេរនូវកម្មវត្ថុថា " ទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុល" បានទេ។

ក្នុងករណីដែលកម្មវត្ថុគឺជាសិទ្ធិលើបំណុលវិញ មូលហេតុដែលម្ចាស់បំណុលចាំបាច់ត្រូវតែកំណត់អំពីកម្មវត្ថុ និង សិទ្ធិលើបំណុលផ្សេងទៀតត្រឹមកម្រិតមួយដែលអាចឲ្យកូនបំណុលទី៣ អាចដឹងដោយងាយស្រួលមានដូចតទៅ។ ពោលគឺ ប្រសិនបើតុលាការអនុវត្តនូវការរឹបអូសជាបណ្ដោះអាសន្ន នោះកូនបំណុលទី៣នឹងត្រូវបានតុលាការហាមឃាត់នូវការសងសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៦៦ កថា.ទី១។ ប៉ុន្តែ ប្រសិនបើមិនអាចដឹងថា តើសិទ្ធិលើបំណុលណាមួយដែលត្រូវបានរឹបអូសទេនោះ ដូច្នេះហើយ ក៏មិនដឹងថា តើត្រូវតែសងនូវសងលើបំណុលណាមួយដែរ ។ ម្យ៉ាងវិញទៀត តើត្រូវរឹបអូសជាបណ្ដោះអាសន្ននូវទ្រព្យសម្បត្តិមួយណានោះតុលាការត្រូវធ្វើការវិនិច្ឆ័យអំពីភាពចាំបាច់ទៅតាមនោះផងដែរ។

ចំពោះអត្ថិភាពនៃកម្មវត្ថុ មិនមែនជាកម្មវត្ថុនៃការសម្រេចសេចក្ដីទេ។ ចំពោះម្ចាស់បំណុលមិនចាំបាច់គិតស្រាវជ្រាវអំពីកម្មវត្ថុថា តើសិទ្ធិលើបំណុលរបស់កូនបំណុលពិតជាមានប្រាកដទេ? នោះទេ។ ហេតុនេះហើយ ប្រសិនបើក្នុងករណីដែលតុលាការធ្វើការរឹបអូសជាបណ្ដោះអាសន្ននូវប្រាក់បញ្ញើក្នុងធនាគាររបស់កូនបំណុល គឺគ្រាន់តែកំណត់អំពីប្រាក់បញ្ញើនោះជាការស្រេច ហើយមិនចាំបាច់សម្រេចថាតើប្រាក់បញ្ញើរបស់កូនបំណុលគឺពិតជាមាននៅសាខានៃធនាគារនោះមែនទេ ? នោះទេ។ ជាការពិតណាស់ ប្រសិនបើជាក់ស្តែងពុំមានប្រាក់បញ្ញើនោះពិតប្រាកដទេ នោះការអនុវត្តនឹងចប់ទាំងទទេចោល ប៉ុន្តែ នេះគឺជារឿងដែលជៀសមិនផុតនោះទេ។

ការរឹបអូសជាបណ្ដោះអាសន្ន គឺជានីតិវិធីដែលកំណត់ជាមុនសម្រាប់ការអនុវត្តដោយបង្ខំនាពេលអនាគត ហេតុនេះហើយមិនអាចយកនូវកម្មវត្ថុដែលមិនអាចអនុវត្តដោយបង្ខំបាន (ចលនវត្ថុដែលហាមឃាត់មិនឲ្យរឹបអូស (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣៨០ ) ឬ សិទ្ធិលើបំណុលដែលហាមឃាត់មិនឲ្យរឹបអូស ( ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣៨២) ) មកធ្វើជាកម្មវត្ថុនោះទេ។

- Slide 15

ឧទាហរណ៍ ក្នុងករណីដែលធ្វើការរឹបអូសជាបណ្ដោះអាសន្ននូវប្រាក់បញ្ញើក្នុងធនាគារ នោះត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់ថា តើរឹបអូសជាបណ្ដោះអាសន្ននូវប្រាក់ចំនួនប៉ុន្មាន?

ក្នុងករណីដែលធ្វើការរឹបអូសជាបណ្ដោះអាសន្ននូវវត្ថុមួយដែលមិនអាចបែងចែកបាន ដូចជាអចលនវត្ថុ នោះតម្លៃនៃកម្មវត្ថុនោះនឹងធ្វើឲ្យសិទ្ធិដែលនឹងត្រូវបានរក្សាការពារមានការកើនឡើង ហេតុនេះក៏ជារឿងដែលជាមិនផុតបានដែរ ហើយទោះបីជាវាមានគម្លាតគ្នាបន្តិចក៏ដោយ ក៏តុលាការត្រូវពិចារណាឲ្យបានល្អិតល្អន់ថា តើមានភាពចាំបាច់ក្នុងការរឹបអូសជាបណ្ដោះអាសន្នលើកម្មវត្ថុនោះដែរឬទេ?

- Slide 16

ផ្ទុយមកវិញ បើមើលពីម្ចាស់បំណុលវិញ គេនឹងច្បាស់ជាយល់ថា ឲ្យតែអាចរក្សាការពារនូវតម្លៃនៃសិទ្ធដែលនឹងត្រូវបានរក្សាការពារបាន ទោះបីជាកម្មវត្ថុអ្វីក៏បានដែរ។

- Slide 17

ឧទាហរណ៍នៃសេចក្តីសម្រេចបញ្ចប់របស់ដីកាសម្រេចដែលបង្គាប់ឲ្យដាក់ប្រាតិភោគមានដូចតទៅ " ម្ចាស់បំណុលត្រូវតែតម្កល់ ឬ ផ្ញើប្រាក់ចំនួន.................ដុល្លារជាប្រាតិភោគ ឲ្យបានត្រឹមថ្ងៃទី ......ខែ...........ឆ្នាំ...........។" ។

- Slide 18

"ដីកាសម្រេចរក្សាការពារខុស" មិនមែនសុទ្ធតែមានន័យថា "ផ្ទុយច្បាប់" នោះទេ ពោលគឺមានន័យថា សិទ្ធិដែលតុលាការទទួលស្គាល់នៅក្នុងការរក្សាការពារ ត្រូវបានតុលាការមិនទទួលស្គាល់នៅក្នុងអង្គសេចក្តី។

- Slide 19

ប្រសិនបើកូនបំណុលបានផ្ញើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន នោះទឡ្ហីករណ៍ដែលអាចបញ្ជាក់ថា កូនបំណុលអាចទទួលបានការលុបចោលនូវការអនុវត្ត គឺមានក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៦៩ ។ ម្យ៉ាងទៀត បើយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៤៧ កថា.ទី១ វិញ ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន គឺជា " ប្រាក់ដែលកូនបំណុលត្រូវផ្ញើ" ហេតុនេះ ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្នមិនអាចឲ្យតតិយជនមកបង់ជំនួសបានទេ។

- Slide 26

នៅក្នុងការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ សិទ្ធិទាមទារឲ្យប្រគល់ ឬ សិទ្ធិទាមទារឲ្យចុះចេញពីវត្ថុ នឹងក្លាយជាសិទ្ធិដែលត្រូវបានរក្សាការពារ ដូច្នេះហើយ គួរតែយកភាគីម្ខាងទៀតនៃសិទ្ធិទាមទារឲ្យប្រគល់ ឬ សិទ្ធិទាមទារឲ្យចុះចេញពីវត្ថុ មកធ្វើជាកូនបំណុល។

- Slide 27

ប្រសិនបើសិទ្ធិដែលត្រូវបានរក្សាការពារគឺជាសិទ្ធិទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជី គួរតែយកភាគីម្ខាងទៀតនៃការទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីមកធ្វើជាកូនបំណុល។

- Slide 29

ឧទាហរណ៍នៃការសរសេរអំពីសិទ្ធិដែលត្រូវបានរក្សាការពារ មានដូចជា " សិទ្ធិទាមទារឲ្យចុះចេញ

ពីអាគារ (ផ្អែកតាមកម្មសិទ្ធិ)" "សិទ្ធិទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ" ជាអាទិ៍។

- Slide 33

នៅក្នុងការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ មូលហេតុដែលនាំឲ្យកំណត់នូវចំនួនប្រាតិភោគដោយយកចំនួនថ្លៃឈ្នួលជាមូលដ្ឋាន គឺដោយសារតែភតិសន្យាបានបញ្ចប់រួចហើយ ប៉ុន្តែ ភតិកៈមិនព្រមចុះចេញ ហេតុនេះ ក៏មានករណីដែលភតិបតីដាក់ពាក្យសុំចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ដែរ។

- Slide 38

មូលហេតុដែលនាំឲ្យការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន មិនអាចធ្វើឡើងបានបើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន មានដូចតទៅ៖

① មានផលប៉ះពាល់ធ្ងន់ធ្ងរចំពោះកូនបំណុល

② មិនមែនជាការត្រៀមសម្រាប់ការអនុវត្តដោយបង្ខំនោះទេ ហេតុនេះហើយ ទោះបីជាឲ្យកូនបំណុលដឹងអំពីខ្លឹមសារនៃពាក្យសុំរក្សាការពារ ក៏មិនមែនមានន័យថា មិនអាចសម្រេចបាននូវគោលបំណងនៃការរក្សាការពារនោះដែរ។

- Slide 41

ត្រង់ចំណុចនេះគួរតែគិតថា ការទាញហេតុផលដោយផ្ទាល់មាត់ជាអាទិ៍ គឺ "ជានីតិវិធីដែលត្រូវតែធ្វើឡើង" ។

- Slide 43

ឧទាហរណ៍នៃសេចក្ដីសម្រេចដែលទាមទារ មានដូចតទៅ " បង្គាប់ឲ្យកូនបំណុល............ជាបណ្ដោះអាសន្នចំពោះម្ចាស់បំណុល" ឬ "កូនបំណុលមិនត្រូវ............" ជាអាទិ៍។

- Slide 44

ឧទាហរណ៍មានការចាត់ចែងជាបណ្ដោះអាសន្នថា " កូនបំណុលមិនត្រូវទៅបរទេសទេ" តាមធម្មតាគេយល់ឃើញថា តាំងពីដើមឡើយ ម្ចាស់បំណុលគឺគ្មានសិទ្ធិហាមឃាត់កូនបំណុលមិនឲ្យចេញទៅបរទេសនោះឡើយ ហេតុនេះ តុលាការមិនអាចចេញដីកាសម្រេចដូចឧទាហរណ៍នេះទេ។ ម្យ៉ាងវិញទៀត ចំពោះការចាត់ចែងជាបណ្ដោះអាសន្នដែលធ្វើឡើងចំពោះរដ្ឋបាល ដូចជា " បង្គាប់ឲ្យសាងសង់ផ្ទះជាបណ្ដោះអាសន្ន" ឬមួយក៏ការចេញសាលក្រមនៅក្នុងបណ្ដឹងអង្គសេចក្ដីទៅផ្នែករដ្ឋបាលថា " បង្គាប់ឲ្យសាងសង់ផ្ទះ (ត្រូវតែអនុញ្ញាតនូវការសាងសង់សំណង់) ក៏តុលាការមិនអាចធ្វើឡើងបានដែរ។

- Slide 45

"អះអាងឲ្យស្មើទៅនឹងកម្រិតនៃនីតិវិធីនៃអង្គសេចក្តី" មានន័យថា ឲ្យម្ចាស់បំណុលអះអាងអំពីអង្គហេតុចម្បងឲ្យបានលម្អិត។

- Slide 46

ចំណុចដែលបានសរសេរនៅក្នុងSlide ថា "ប្រសិនបើធ្វើការពិចារណាដោយប្រៀបធៀបនូវការខាតបង់ផលប្រយោជន៍ដែលនឹងកើតឡើងចំពោះម្ចាស់បំណុលដោយសារតែការមិនបានបង្គាប់ឲ្យចាត់ចែងជាបណ្តោះអាសន្ន ជាមួយនឹងការខាតបង់ផលប្រយោជន៍ដែលនឹងកើតឡើងចំពោះកូនបំណុលដោយសារតែការចាត់ចែងជាបណ្តោះអាសន្ន ឃើញថា ម្ចាស់បំណុលមានការខាតបង់ផលប្រយោជន៍ច្រើនជាង នោះមានន័យថា មានភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្ន" ពោល ការលើកឡើងបែបនេះ គឺជាការគិតមួយដោយផ្អែកទៅលើភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្នឲ្យបានគ្រប់ពេល។

ចំណុចដែលត្រូវប្រុងប្រយ័ត្នជាពិសេសនៅពេលធ្វើការវិនិច្ឆ័យអំពី ភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្ន គឺ នៅពេលដែលមានការទាមទារឲ្យចុះចេញពីអចលនវត្ថុជាបណ្តោះអាសន្ន។ ដោយសារតែជាធម្មតា ប្រសិនបើម្ចាស់បំណុលគ្រាន់ទទួលបាននូវការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ហើយរង់ចាំនូវសាលក្រមអង្គសេចក្តី រួចហើយទើបអនុវត្ត គឺជាការគ្រប់គ្រាន់។ ហេតុនេះ ម្ចាស់បំណុលមិនចាំបាច់ទាមទារឲ្យមានការប្រគល់នៅក្នុងការចាត់ចែងជាបណ្តោះអាសន្ននោះទេ។ ប៉ុន្តែ ក៏មានករណីលើកលែងដែរ ដូចជា នៅពេលដែលអាចនឹងមានការរារាំងមិនឲ្យអនុវត្តជាដើម។

- Slide 47

ចំនួននៃការសួរ មិនកំណត់ទេ។ នៅក្នុងរឿងក្តីដែលមានលក្ខណៈស្មុគស្មាញហើយមានចំណុចវិវាទច្រើន អាចសួរច្រើនដងត្រឡប់ទៅត្រឡប់មកបាន។

សូមអរគុណ